# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបិទឆ្នាំសិក្សានៅទេវៈ
# ថ្ងៃទី២២ មិថុនា ២០១៧

អត្ថបទទី១៖២ករ ១១,១-១១
ដំណឹងល្អ៖មថ ៦,៧-១៥

បងប្អូនជាទីស្រឡាញ់!

សន្តម៉ារីយ៉ាណេ ជាមនុស្សម្នាក់ដែលរៀនមិនសូវពូកែ ប៉ុន្តែអាចធ្វើបូជាចារ្យបាន គាត់យកពេលច្រើនដើម្បីអធិដ្ឋាន និងដើម្បីធ្វើអគ្គសញ្ញាលើកលែងទោស។ នៅក្នុងអត្ថបទទីមួយ លោកប៉ូលបានណែនាំជីវិតជាបូជាចារ្យ និងនិស្សិតទេវៈដែលជាកូនបូជាចារ្យ បាននិយាយថា **តើមកពីខ្ញុំមិនស្រឡាញ់បងប្អូនឬ? ព្រះជាម្ចាស់ជ្រាបហើយថាខ្ញុំស្រឡាញ់បងប្អូន** ជាមូលហេតុលោកប៉ូល ហ៊ាននិយាយច្រើនទៅក្រុមនីមួយៗពេលគាត់ទៅសួរសុខទុក្ខ។ ខ្ញុំស្រឡាញ់បងប្អូន ត្រូវតែទៅជាជីវិតរបស់យើងជាបូជាចារ្យ។ យ៉ូហានម៉ារីយ៉ាណេ បានស្រឡាញ់បងប្អូនគ្រីស្តបរិស័ទ ដែលគាត់បានទទួលពីព្រះសហគមន៍តូចរបស់គាត់។ អ្វីដែលបានណែនាំសន្តម៉ារីយ៉ាណេ គឺព្រះបន្ទូលមួយថា **ប្រសិនបើម្នាក់ចង់ដើរតាមខ្ញុំ ត្រូវការលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនលីឈើឆ្កាងនិងដើរតាមខ្ញុំ** នេះជាអ្វីដែលបានណែនាំជីវិតរបស់គាត់។ គាត់បានទទួលឈើឆ្កាងច្រើន គាត់លះបង់ច្រើនដើម្បីទទួលតែងតាំងជាបូជាចារ្យ ក្រោយមកលោកអភិបាលបានបញ្ជូនគាត់ទៅភូមិតូចមួយដោយសារគាត់មិនសូវពូកែមិនសូវឆ្លាត ប៉ុន្តែគាត់បានលីឈើឆ្កាងដើម្បីដើរតាមព្រះយេស៊ូ។ ជីវិតរបស់គាត់បានខិតខំអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយយកចិត្តទុកដាក់ការពារថែរក្សាជីវិតជាអ្នកក្រីក្រ។ សម្រាប់យើងដែលរស់នៅក្នុងព្រះសហគមន៍ប្រទេសកម្ពុជា យើងត្រូវការសួរខ្លួនឯងថា **ធ្វើដូចម្តេចដើម្បីការពារថែរក្សាជីវិតជាអ្នកក្រីក្រ?** លោកយ៉ូហានម៉ារីយ៉ាណេ ពេលគាត់ទទួលស្វាគមន៍អ្នកតូចតាចម្នាក់ដែលគោះទ្វារនៅផ្ទះគាត់ គាត់បានទទួលស្វាគមន៍យ៉ាងសប្បាយចិត្ត ដោយនិយាយថា **ខ្ញុំជាអ្នកក្រីក្រដូចលោក ដូច្នេះថ្ងៃនេះខ្ញុំដូចលោកហើយ។** សម្រាប់ជីវិតរបស់យើងសព្វថ្ងៃមិនស្រួលប៉ុន្មានទេ ដើម្បីបង្ហាញអំពីរបៀបដែលព្រះយេស៊ូណែនាំឲ្យយើងលះបង់ចោល។ ប៉ុន្តែ យើងអាចលះបង់ចោលតាមផ្លូវវិញ្ញាណយ៉ាងស្រួល ប៉ុន្តែធ្វើដូចម្តេចដើម្បីឲ្យបងប្អូនឯទៀតៗអាចទទួលស្គាល់ដែរ និងឲ្យគេយល់ថាយើងស្រឡាញ់គេ។ សន្តយ៉ូហានម៉ារីយ៉ាណេ ធ្លាប់និយាយនៅថ្ងៃចុងក្រោយរបស់គាត់ថា **ខ្ញុំ**

**សប្បាយចិត្តណាស់ ដោយសារខ្ញុំលែងមានអ្វីៗទាំងអស់ ព្រះជាម្ចាស់អាចត្រាស់ហៅខ្ញុំនៅថ្ងៃណាក៏បាន** គាត់បានផ្ញើអ្វីៗទាំងអស់ទៅព្រះជាម្ចាស់ ដោយបានរៀបចំខ្លួនទៅជួបជាមួយព្រះជាម្ចាស់ផ្ទាល់។

គាត់បានយកចិត្តទុកដាក់ដើម្បីការពារជីវិតជាព្រហ្មចារី គាត់ត្រូវការមានចិត្តគំនិតបរិសុទ្ធ ដើម្បីណែនាំឲ្យបងប្អូនអាចរកឃើញប្រភពនៃសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់។ គាត់ធ្លាប់និយាយច្រើនដងថា **ជីវិតជាបូជាចារ្យ គឺស្រឡាញ់ព្រះបេះដូងរបស់ព្រះយេស៊ូ។** យកបេះដូងរបស់ព្រះយេស៊ូជាជីវិតរបស់យើងតែម្តង ដើម្បីណែនាំឲ្យមនុស្សយ៉ាងច្រើនស្គាល់ព្រះយេស៊ូ ស្រឡាញ់ព្រះយេស៊ូនិងទទួលជីវិតថ្មីដោយសារព្រះយេស៊ូ។

គាត់បានយកចិត្តទុកដាក់ ដើម្បីស្តាប់បង្គាប់ព្រះសហគមន៍ គាត់រស់នៅក្នុងព្រះសហគមន៍ សម្រាប់ព្រះសហគមន៍ បរិយាកាសនៃជីវិតរបស់គាត់គឺព្រះសហគមន៍។ អ្វីដែលគាត់ទទួលគឺមាតារបស់គាត់ជាព្រះសហគមន៍ ដើម្បីបម្រើបងប្អូនឯទៀតៗ និងដើម្បីណែនាំឲ្យគ្រីស្តបរិស័ទរស់នៅក្នុងសេចក្តីសុខនៅក្នុងព្រះសហគមន៍។ សម្រាប់យើងដែលជាព្រះសហគមន៍តូចមួយនៅប្រទេសកម្ពុជា ប៉ុន្តែយើងរស់នៅក្នុងព្រះសហគមន៍សម្រាប់ព្រះសហគមន៍ ដើម្បីបម្រើបងប្អូនឯទៀតៗ។

គាត់បានយកចិត្តទុកដាក់ ធ្វើជាបូជាចារ្យម្នាក់ដែលអធិដ្ឋានជីវិតរបស់គាត់គឺអធិដ្ឋាន។ គាត់ធ្លាប់និយាយថា **មនុស្សយើងជាអ្នកក្រីក្រដែលត្រូវការតែទូលអង្វរទៅព្រះជាម្ចាស់ ដើម្បីឲ្យព្រះជាម្ចាស់កែប្រែចិត្តគំនិតរបស់យើង តាមរបៀបដែលយើងទូលអង្វរព្រះអង្គពីមួយថ្ងៃទៅមួយថ្ងៃ។** គេឃើញគាត់ច្រើនដងនៅពេលអធិដ្ឋាន គាត់ធ្លាប់និយាយច្រើនដងថា **ជីវិតរបស់ខ្ញុំ គឺខ្ញុំដឹងថាព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ខ្ញុំមានចិត្តតែមួយជាមួយព្រះជាម្ចាស់ ខ្ញុំរស់នៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ ខ្ញុំរស់សម្រាប់ព្រះជាម្ចាស់ ជីវិតរបស់ខ្ញុំស្អាត់ណាស់ និងសេចក្តីស្លាប់របស់ខ្ញុំក៏ស្អាតដូចគ្នា។** ជីវិតនៅក្នុងព្រះជាម្ចាស់ មិនថារស់នៅលើផែនដីនេះ ឬស្លាប់គឺនៅជាមួយព្រះជាម្ចាស់។ ទោះបីជាជីវិតរបស់យើងរវល់យ៉ាងណាក៏ដោយ យើងធ្វើដូចម្តេចដើម្បីឲ្យយើងថែរក្សា ជីវិតនិងទំនាក់ទំនងជាមួយព្រះជាម្ចាស់ជានិច្ច។

យ៉ូហានម៉ារីវីយ៉ាណេ គាត់បានយកចិត្តទុកដាក់នៅក្នុងភូមិគាត់យ៉ាងច្រើនដើម្បីឲ្យមានសាលារៀនសម្រាប់ក្មេងៗក្រីក្រ យកចិត្តទុកដាក់ជាមួយអ្នកជំងឺ អ្នកដែលកំពុងខ្វះ

ខាត គាត់បានយកចិត្តទុកដាក់ប្រកាសដំណឹងល្អពីភូមិមួយទៅភូមិមួយ នៅជុំវិញកន្លែងដែលគាត់នៅ ដើម្បីឲ្យគេស្គាល់ព្រះជាម្ចាស់។ គាត់ចាប់អារម្មណ៍អំពីសេចក្តីត្រូវការរបស់មនុស្ស ជាពិសេសសេចក្តីត្រូវការរបស់គ្រីស្តបរិស័ទដែលគាត់ទទួលខុសត្រូវ។ គាត់មានការទទួលខុសត្រូវយ៉ាងខ្ពស់ ដោយសារគាត់ជាគ្រូគង្វាលដ៏សប្បុរស ដោយមានចិត្តគំនិតតែមួយជាមួយបងប្អូនដែលគាត់ទទួលខុសត្រូវ អាចទទួលជីវិតថ្មី ទទួលការសង្គ្រោះ មានសេចក្តីសុខសាន្តនៅក្នុងព្រះជាម្ចាស់ និងបន្តកែប្រែចិត្តគំនិត កុំឲ្យភ្ជាប់ជាមួយអំពើបាប តែផ្ទុយទៅវិញឲ្យគេរកឃើញសេចក្តីស្រឡាញ់ ដែលមានព្រះជាម្ចាស់នៅក្នុងជីវិតគេ។

យ៉ូហានម៉ារីយ៉ាណេ ជាមនុស្សម្នាក់ដែលពូកែទេសនា និងពូកែអប់រំជំនឿ មិនមែនដោយសារគាត់មានចំណេះដឹងខ្ពស់ ប៉ុន្តែនៅពេលគេស្តាប់គាត់ទេសនាបីដូចជា មានព្រះជាម្ចាស់គង់នៅជាមួយគាត់តែម្តង។ ដូច្នេះពាក្យនីមួយៗដែលគាត់និយាយ ប្រៀបដូចជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលជ្រាបចូលនៅក្នុងដួងចិត្តរបស់គ្រីស្តបរិស័ទដែលកំពុងស្តាប់គាត់។ គាត់ធ្វើដូចម្តេច ដើម្បីឲ្យពាក្យដែលចេញពីបេះដូងរបស់គាត់ ពិតមែនអាចចូលនៅក្នុងដួងចិត្តរបស់គ្រីស្តបរិស័ទដែលស្តាប់គាត់ បីដូចជាព្រះបន្ទូលរបស់ព្រះយេស៊ូផ្ទាល់ដែលណែនាំឲ្យគេសប្បាយចិត្ត។ គេស្តាប់គាត់ដូចស្តាប់ព្រះគ្រីស្តផ្ទាល់ ដោយសារគាត់បានភ្ជាប់ជាមួយព្រះយេស៊ូ ដោយសារពាក្យនីមួយៗដែលគាត់និយាយគឺចេញពីជំនឿរបស់គាត់ និងចេញពីបទពិសោធន៍ដែលគាត់មានជាមួយព្រះយេស៊ូ និងជាមួយបងប្អូនឯទៀតៗដែលទទួលស្គាល់ថា ជាព្រះគ្រីស្តដែលកំពុងមានវត្តមាននៅក្នុងជីវិតរបស់គាត់។ គាត់អង្គុយផ្តល់អគ្គសញ្ញាលើកលែងទោសឲ្យគេ ១៥ម៉ោងក្នុងមួយថ្ងៃ។

ជីវិតរបស់យ៉ូហានម៉ារីយ៉ាណេ ជាជីវិតមួយដែលណែនាំឲ្យយើងជាបូជាចារ្យ ជានិស្សិតទេវៈវិទ្យាល័យ ពីមួយឆ្នាំទៅមួយឆ្នាំកាន់តែរីកចម្រើននៅក្នុងសេចក្តីស្រឡាញ់ជាមួយព្រះយេស៊ូ និងយកពេលដើម្បីនឹកឃើញជីវិតរបស់សន្តយ៉ូហានម៉ារីយ៉ាណេ ជាឱកាសមួយដើម្បីមានកម្លាំងថ្មី ដើម្បីបន្តរៀបចំខ្លួនឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ខ្ញុំក៏សូមអរគុណដល់លោកឪពុក ដែលបានទទួលនិស្សិតទេវៈវិទ្យាល័យដើម្បីចុះតាមកន្លែងនីមួយៗ និងលោកឪពុកដែលស្ម័គ្រចិត្តជួយបង្រៀននៅទេវៈ ដើម្បីឲ្យនិស្សិតទេវៈវិទ្យាល័យអនុវត្តអ្វីដែលយ៉ូហានម៉ារីយ៉ាណេបានធ្វើ ដោយអធិដ្ឋាន ដោយយកចិត្តទុកដាក់ជាមួយបងប្អូន និងធ្វើដំណើរជាមួយបងប្អូននៅក្នុងព្រះគ្រីស្ត។ អាម៉ែន៕